00780485

E138/1/7/3

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception):
20 / 02 / 2012
ម៉ោង (Time/Heure): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អនុស្សរណៈ-អង្គជំនុំជម្រះសាលាដំបូង

**ជូនចំពោះ:** ភាគីទាំងអស់នៃសំណុំរឿង ០០២ កាលបរិច្ឆេទ: ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២

**ពី:** Susan Lamb មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង,

**កម្មវត្ថុ:** ការធ្វើបច្ចុប្បន្នភាពបន្ថែម ពាក់ព័ន្ធនឹងសេចក្តីបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងទៅអ្នកជំនាញវេជ្ជសាស្ត្រដោយស្នើសុំព័ត៌មានថ្មីៗទាក់ទិននឹងជនជាប់ចោទ អៀង ធីរិទ្ធ

កាលពីថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានយល់ព្រមពន្យារពេលរហូតដល់ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១២ សម្រាប់ឱ្យអ្នកជំនាញវេជ្ជសាស្ត្រដែលធ្លាប់បានវាយតម្លៃជនជាប់ចោទ អៀង ធីរិទ្ធ ដាក់របាយការណ៍ស្តីពីព័ត៌មានវេជ្ជសាស្ត្រពាក់ព័ន្ធនានាមកអង្គជំនុំជម្រះ ដែលមានចាប់តាំងពីពេលជនជាប់ចោទ អៀង ធីរិទ្ធ បានទទួលការពិនិត្យលើកចុងក្រោយនៅខែ កញ្ញា ឆ្នាំ ២០១១ និងអនុសាសន៍សម្រាប់ការព្យាបាលបន្ថែម ដែលអាចធ្វើឱ្យជនជាប់ចោទមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការ (ឯកសារ E138/1/7/2)។ កាលពីថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ អ្នកជំនាញបានស្នើសុំពន្យារពេលក្នុងការដាក់របាយការណ៍របស់ខ្លួនរហូតដល់ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១២។ អ្នកជំនាញបានកត់សម្គាល់ឃើញថា បន្ទាប់ពីមានការពិនិត្យយ៉ាងយកចិត្តទុកដាក់ទៅលើកំណត់ហេតុវេជ្ជសាស្ត្ររបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក៏ដូចជាការពិគ្រោះយោបល់ជាមួយវេជ្ជបណ្ឌិតព្យាបាលជនជាប់ចោទ និងការពិភាក្សាប្តូរយោបល់ក្នុងចំណោមអ្នកជំនាញ អ្នកជំនាញបានពិចារណាឃើញថា ការពិនិត្យផ្ទាល់ទៅលើជនជាប់ចោទពីសំណាក់អ្នកជំនាញមួយចំនួន ក្នុងចំណោមអ្នកជំនាញទាំងអស់

ជាការចាំបាច់ មុនពេលពួកគាត់អាចផ្តល់អនុសាសន៍ជូនអង្គជំនុំជម្រះ។ ហេតុដូច្នេះ អ្នកជំនាញបានធ្វើការពិនិត្យល្អិតល្អន់ជាថ្មីទៅលើជនជាប់ចោទ អៀង ធីរិទ្ធ កាលពីថ្ងៃទី ២-៣ ខែ កុម្ភៈ ឆ្នាំ ២០១២។ អ្នកជំនាញកំពុងបញ្ចប់របាយការណ៍របស់ខ្លួន ដោយរួមបញ្ចូលទាំងអនុសាសន៍របស់អ្នកជំនាញវេជ្ជសាស្ត្រ ដែលបានទទួលការតែងតាំងពីអង្គជំនុំជម្រះ។ អង្គជំនុំជម្រះសាលាដំបូងបានឯកភាពឲ្យមានការពន្យារការដាក់របាយការណ៍ខាងលើ រហូតដល់ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១២ តាមសំណើសុំ។